ខ្មែរប៉ុស្តិ៍ ស.រ.អា

KhmerPost USA

Printing The Cambodian World News

VOL. 06 ISSUE 93 Oct 29th - Nov12th, 2011

សុបិន : (267) 253-3947, សែម : (781) 244-0522

MASSACHUSETTS
217 APPLETON ST.
LOWELL, MA 01852
PENNSYLVANIA
438 LINDLEY AVE.
PHILADELPHIA, PA 19120
RHODE ISLAND
NEW JERSEY

| មាតិការរឿង | ទំព័រ |
| --- | --- |
| ១-សម្បត្តិនៃមនុស្សចាស់ | ០៣ |
| ២-ខួបទី២០នៃសន្ធិសញ្ញាក្រុងប៉ារីស | ០៦ |
| ៣-លោក កឹម សុខា បក្សកាន់អំណាចកំពុងដឹករណ្តៅកប់ខ្លួនឯង | ១២ |
| ៤- ប្រវត្តិសាស្ត្រកម្ពុជា | ១៤ |
| ៥- The Cambodia Daily | ០៦ & ១៣ |

# កឋិនទាននៅហ្វីឡាដែលហៀ







ត្រៃឆ្វេងគ្រួសារ ធុយ សំណាង ត្រៃកណ្តាលលោកស្រី ហ៊ុយ គៀវអឹង ត្រៃស្តាំលោក លោកស្រី សុង ហុងអេង

**ដោយ : ខ្មែរប៉ុស្តិ៍**

វត្តព្រះពុទ្ធវង្សី កាលពីថ្ងៃអាទិត្យទី២៣តុលានេះ បានសម្តែងនូវបដិហារថ្មីមួយទៀត នាឱកាសធ្វើបុណ្យកឋិនសម្រាប់ហែរចូលវត្ត ។ ពុទ្ធបរិស័ទប្រមាណ៨០០-១០០០នាក់ បាននាំគ្នាដង្ហែរត្រៃចំនួន២០០មាន ត្រៃកណ្តាល ត្រៃឆ្វេង ត្រៃស្តាំ ដង្ហែរតាមដងផ្លូវ ដែលមានទីពាណិជ្ជកម្មខ្មែរផ្លូវលេខ៧ ទៅមកនៅផ្លូវ "ស្នាយឌែ" រួចត្រឡប់មកវត្តវិញតាមផ្លូវលេខ៦ ដែលមានសួនឧទ្យានកូនខ្មែរចូលចិត្តទៅកំសាន្តដែលពិធីដ៏ឧឡារិកនេះបានបណ្តាលឱ្យមានចិត្តរីករាយមានចិត្តសទ្ធាចូលរួមចូលបច្ច័យសំរាប់កសាងព្រះពុទ្ធសាសនាតាមរយៈវត្តព្រះពុទ្ធវង្សីនោះបានចំនួន៧ម៉ឺន ៦ពាន់ដុល្លារ ។

ចំនួនប្រាក់ដ៏ច្រើនទទួលបានពីចិត្តសទ្ធាជ្រះថ្លារបស់ពលរដ្ឋខ្មែរ ដែលភាគច្រើនជាមនុស្សចាស់ហើយក្រីក្រ គឺជាអំណោយដែលចេញពីទឹកចិត្តរីករាយ និងបរិសុទ្ធកាត់ថ្លៃមិនបាន ។ វត្តមួយនេះបានធ្វើឱ្យពលរដ្ឋនិយាយពីមាត់មួយទៅមាត់មួយថា បានប្រកាន់វិន័យយ៉ាងតឹងតែង និងខ្ជាប់ខ្ជួន ហើយមានភាពសុច្ចរិតយុត្តិធម៌មិនអាចប្រកែកបានដោយសារការប្រកាន់តម្លាភាព និងការបែងចែកការទទួលខុសត្រូវដាច់ៗពីគ្នា ហើយអាចត្រួតពិនិត្យគ្នាបានទៀតផង ។ គំរូមួយទៀតដែលជាហេតុបង្កើតចិត្តសទ្ធាជ្រះថ្លាដ៏ពុះពាររបស់ឧបាសកឧបាសិការ **តទៅទំព័រទី០៩**

# វត្តត្រៃរតនារាមឡើងតុលាការសារជាថ្មី

**ដោយ : ពិន សំខុន**

**ឡូវែល :** ភ្នំភ្លើងកំហឹងបានឆេះឆួលសាជាថ្មីនាវត្តត្រៃរតនារាម បន្ទាប់ពីបានស្ងប់ស្ងាត់មួយរយៈចាប់ពីដើមឆ្នាំ២០១១ មកទល់ដើមខែតុលានេះមក ។ គណកម្មាធិការថ្មីថ្មោងកើតឡើងពីបញ្ជាតុលាការឱ្យសមាជិកវត្តក្រោម និងសមាជិកវត្តលើរំលាយបញ្ចូលគ្នាតែមួយ ហើយយកអាជ្ញាប័ណ្ណវត្តត្រឡប់មកកាន់កាប់ដោយវត្តត្រៃរតនារាមវិញ ពុំមែនកាន់កាប់ដោយសហគមន៍ព្រះសង្ឃខ្មែរទៀតទេ ។ នាសប្តាហ៍កន្លងទៅនេះគណកម្មាធិការនោះមិនត្រឹមតែថ្មីថ្មោងទេ ថែមទាំងផុតស្រួយរហែកជាពីរបង្កើតជាវិវាទដ៏ធំធេងថ្មីមួយទៀត គឺគណកម្មាធិការនោះបានដាក់ពាក្យបណ្តឹងទៅតុលាការ "ទាមទារឱ្យបញ្ឈប់សកម្មភាពបោះឆ្នោតខុសច្បាប់ជ្រើសរើសគណកម្មាធិការនាយកថ្មី ដោយលោក អ៊ុងរិទ្ធី បញ្ឈប់ការប្រើអាស័យដ្ឋានវត្តត្រៃរតនារាមជាអាស័យដ្ឋានផ្លូវច្បាប់របស់សហគមន៍ព្រះសង្ឃខ្មែរ ដែលមានព្រះតេជគុណ សៅ ឃន ជាប្រធាននឹងបញ្ឈប់ការប្រមូលថវិកានៅក្នុងវត្ត" បន្ថែមពីនោះទៅទៀតពាក្យបណ្តឹងនោះមាន "ទាមទារឱ្យតុលាការបណ្តេញសហគមន៍ព្រះសង្ឃខ្មែរ ចេញពីវត្តត្រៃរតនារាម" ថែមទៀត។ **តទៅទំព័រទី១០**




ដីវត្តថ្មី

# ប្រមុខរដ្ឋាភិបាលម្នាក់ទៀតត្រូវរាស្ត្រសម្លាប់

**ដោយ : ខ្មែរប៉ុស្តិ៍**



© Getty Images

**ប្រទេសលីប៊ីយ៉ា :** យន្តហោះប្រដេញបារាំងនៃកងទ័ព "ណេតូ" បានចេញធ្វើបេសកកម្មរារាំងមិនឱ្យក្បួនរថយន្តកងទ័ពមួយធ្វើដំណើរទៅមុខបាន ដែលគេជឿថា ក្នុងនោះអាចមានវរសេនីយ៍ កាដាហ្វី នៅក្នុងនោះ នាពេលព្រឹកម៉ោង ៨:៣០ ថ្ងៃ២២ តុលា ឆ្នាំ ២០១១ នេះ នៅទីក្រុង "សៀត" ភូមិកំណើតរបស់ កាដាហ្វី ។ ដោយមានការវាយប្រហារកាន់តែខ្លាំងឡើងនៅ សៀត ដែល កាដាហ្វី គេចខ្លួនទៅទីនោះពីសំណាក់របស់ទ័ពឧទ្ទាមប្រជារាស្ត្រលីប៊ីយ៉ា បះបោរគាំទ្រដោយកងទ័ពណេតូ វរសេនីយ៍ កាដាហ្វី ប្រមុខរដ្ឋាភិបាលកាន់អំណាចយ៉ាងផ្តាច់ការចំនួន ៤២ឆ្នាំមកហើយ បានសម្រេចគេចខ្លួនពីសង្កាត់លេខពីរទៅទីកន្លែងផ្សេងតែយន្តហោះប្រដេញមីរ៉ាស៍២០០០ បារាំងបានបាញ់បង្អាក់ដំណើរពីមុខក្បួនទ័ពកាដាហ្វីនោះ ។ ទន្ទឹមគ្នានោះដែរ កងប្រដាប់អាវុធឧទ្ទាមក៏បានបាញ់ចម្រុះទៅលើក្បួនរថយន្តនោះ បណ្តាលឱ្យក្បួនរថយន្តរងការស្ទាក់បាញ់ ហើយរថក្រោះ កាដាហ្វី ក៏បានរងគ្រាប់រុកកែតយ៉ាងដំណំដែរ ។ កងការពារបានជន្លៀស កាដាហ្វី ចេញពីរថក្រោះទៅរកជម្រកផ្សេងតែពេលនោះវរសេនីយ៍ ប្រមុខរដ្ឋអស់ល័ក្ខណ៍បានត្រូវគ្រាប់នៅក្បាលមួយគ្រាប់ និងជើងមួយគ្រាប់របស់កងឆ្មក់ឧទ្ទាមរួចទៅ ហើយមុននឹងទៅលាក់ខ្លួននៅលូបង្ហូរទឹកមួយនៅចិញ្ចើមថ្នល់ ។

នៅពេលកងទ័ពឧទ្ទាមប្រជារាស្ត្រចូលទៅចាប់ខ្លួនកាដាហ្វីពីលូបង្ហូរទឹកចេញមកសាក្សីបាននិយាយថា កាដាហ្វី បានសុំឱ្យទុកជីវិតតែ **តទៅទំព័រទី១៦**

# យើងនៅរង់ចាំជួយដល់លោកអ្នក!

●● ប្រសិនបើលោកអ្នក :

- មានអារម្មណ៍អស់សង្ឃឹម ឬរំភើបខ្លាំង
- មានភាពធាប់ទឹង
- ចង់នៅតែឯកឯង
- មានទឹកចិត្តផ្លាស់ប្តូរ
- មានភាពច្របូកច្របល់ក្នុងខ្លួន
- មានអារម្មណ៍ធុញថប់
- មានអារម្មណ៍រំជួលចិត្ត ឬព្រួយបារម្ភ
- ផ្លាស់ប្តូរទម្លាប់ដំណេក
- ផ្លាស់ប្តូរទម្លាប់បរិភោគ
- យំច្រើន
- ឮសម្លេងដែលមិនមានពិតប្រាដក
- ឃើញរូបភាពដែលមិនពិត
- មានគំនិតចង់ធ្វើឲ្យឈឺចាប់ខ្លួនឯង ឬឈឺចាប់ដល់អ្នកដ៏ទៃ
- មានគំនិតចង់សម្លាប់ខ្លួន



យើងនិយាយភាសាខ្មែរ

## សូមទូរស័ព្ទរក រដ្ឋា ម៉ាក់ធ្វី
## ដើម្បីជួយឱ្យបានទទួលសេវាសុខភាពផ្លូវចិត្ត

**215-413-3100**

extension **5156**

Provided by:
Department of Behavioral Health and Intellectual disAbility Services
Arthur C. Evans, Ph.D., Commissioner

DBHIDS DEPARTMENT of BEHAVIORAL HEALTH and INTELLECTUAL disABILITY SERVICES
Recovery · Resilience · Self-Determination

C·B·H

CITY OF PHILADELPHIA · LIFE · LIBERTY · AND YOU



# New Century Auto
*Collision & Service Center*

17 South Street, Lowell MA 01852

Telephone: (978) 710 - 3488







-ទទួលជួសជុលតួរថយន្ត ម៉ាស៊ីន បាញ់ថ្នាំ ប្រព័ន្ធភ្លើង ប្រព័ន្ធម៉ាស៊ីនត្រជាក់ ដោយជាងមានបទពិសោធន៍ច្បាស់លាស់យូរឆ្នាំ

-ឧបករណ៍ Technology ថ្មីបំផុតទទួលស្គាល់ដោយក្រុមហ៊ុន BMW Lexus Mercedes

**AUTO BODY SERVICES**

- -លាយថ្នាំដោយប្រព័ន្ធ Computer ធានាដូច១០០%(នៅទីនេះ)
- -ឧបករណ៍បាញ់ថ្នាំដើរដោយប្រព័ន្ធ Computer
- -ជួសជុលរថយន្ត គ្រោះថ្នាក់ ប៉ះទង្គិច ឱ្យបានល្អស្អាតដូចដើម១០០%

**REPAIR-MAINTENANCE**

- -ជួសជុលគ្រឿងម៉ាស៊ីន គ្រឿងក្រោម តាមលក្ខណៈបច្ចេកទេស
- -ទទួលប៉ះកង់ ដូរកង់ ដូរប្រេង ដូរហ្វ្រាំង ពិនិត្យប្រព័ន្ធ បំពង់ខ្យល់ បំពង់ទឹក
- -ជួសជុលប្រព័ន្ធ AC&Hit ជាទីទុកចិត្ត

ស្មោះត្រង់ ទាន់ចិត្ត សុវត្ថិភាព

តម្លៃសមរម្យ គុណភាពខ្ពស់



-យានដ្ឋានយើងខ្ញុំទទួលស្គាល់ដោយក្រុមហ៊ុនធានារ៉ាប់រងជាច្រើន (Mass,Hanover,Commerce,Trust,Arbella,Metropolitan,Safetygroup)

-ទទួលធ្វើការទំនាក់ទំនងជាមួយក្រុមហ៊ុនធានារ៉ាប់រង ជូនលោកអ្នកជាទីទុកចិត្ត

**រថយន្តល្អ សុវត្ថិភាព ជីវិតរុងរឿង អនាគតភ្លឺថ្លា !**

# សម្បត្តិនៃមនុស្សចាស់ (ត)

**ដោយ : ពិន សំខុន**

កាលពីលេខមុនខ្មែរប៉ុស្តិ៍បាននិយាយថា ចាស់ៗខ្មែរ ទោះជាមាន ឬក្រប៉ុណ្ណា ចេះដឹង ឬមិនចេះប៉ុណ្ណា មានជម្ងឺ ឬសុខភាពល្អប៉ុណ្ណា សុទ្ធសឹងតែមានសមត្ថភាព និងលទ្ធភាពជាជំនួយដល់កូនចៅជំនាន់ក្រោយបានទាំងអស់គ្នា ឱ្យតែខ្លួនឯងខិតខំយល់ដឹងពីបទពិសោធន៍ក្នុងជីវិតដ៏ច្រើនសន្ធឹករបស់ខ្លួន ហើយយកមកប្រើប្រាស់ប្រកបដោយក្តីស្រឡាញ់ និងប្រកបដោយវិជ្ជមាន។

ព្រះតេជគុណចៅអធិការ រដ្ឋ មុនី នៃវត្តព្រះពុទ្ធរង្សីខាងត្បូងក្រុងហ្វីឡាដែលហ្វៀ បានណែនាំឱ្យខ្មែរប៉ុស្តិ៍ ស.រ.អា បានជួបគណកម្មាធិការនាយករបស់សមាគមមួយឈ្មោះ **"មរណសង្គហសមាគម"** ដែលមានទីតាំងនៅវត្តព្រះពុទ្ធរង្សី មានប្រធានឈ្មោះ ស៊ិន សុវណ្ណ អនុប្រធានឈ្មោះ ចាន់ សុខុម និងហិរញ្ញិកឈ្មោះ ឈឿន ផល ។ សមាគមនេះកំពុងផ្តល់ភាពរឹងប៉ឹងដូចជា សម្បត្តិមួយទៀតដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងតំបន់ គឺចាស់ៗអាចរៀបចំគ្រោងសេចក្តីស្លាប់របស់ខ្លួន ឱ្យអាចប្រព្រឹត្តទៅបានក្នុងកិត្តិយស និងប្រពៃណីដែលក្រុមគ្រួសារក្រីក្រ និងមធ្យម ឬក៏គ្រប់គ្រាន់ត្រូវការចាំបាច់សំរាប់បញ្ចប់កង្វល់រាល់ថ្ងៃរបស់អ្នកដែលមានមាតាបីតា ឬជីដូនជីតាជរានៅក្នុងបន្ទុក។

លោក ស៊ិន សុវណ្ណ បាននិយាយថា "មរណសង្គហសមាគម" មានបំណងជួយសម្រួលកិច្ចការសមាជិកខ្លួននៅពេលសមាជិកនោះមានមនុស្សស្លាប់ក្នុងគ្រួសារ ។ ព្រះតេជគុណ រដ្ឋ មុនី និងលោក ស៊ិន សុវណ្ណ បានជួយបង្រួប់ប្រយោគគ្នាថា :

១.សមាគមជួយរកទីកន្លែងតំកល់សពដូចជា "Funeral Home"

២.ជួយធ្វើលិខិតស្របច្បាប់សម្រាប់ពិធីឈាបនកិច្ច



ព្រះតេជគុណ រដ្ឋ មុនី



ចាន់ សុខុម ស៊ិន សុវណ្ណ

៣.ជួយធ្វើពិធីបុណ្យតាមប្រពៃណីខ្មែរ ផ្តល់ទីកន្លែងសមរម្យសម្រាប់ធ្វើបុណ្យ មានព្រះសង្ឃ និងអាចារ្យដែលដឹកនាំពិធីបុណ្យសពដង្ហែសពទៅបូជា ឬបញ្ចុះទៅតាមការផ្តែរផ្តាំរបស់សព ឬបំណងក្រុមគ្រួសារ និងតំកល់អដ្ឋិធាតុជូននៅវត្តបានផង។

នៅលើសំណួរថា នរណាជាអ្នកចេញថ្លៃនៃពិធីអស់ទាំងនោះ? លោក ស៊ិន សុវណ្ណ បានតបថា "ករណីធ្លាប់មានមកហើយមានពីរប្រភេទ គឺចំពោះអ្នកជាសមាជិកមរណសង្គហសមាគម" និងអ្នកដែលមិនមែនជាសមាជិក។

**ចំពោះអ្នកដែលជាសមាជិក :** នោះសមាគមនឹងផ្តល់ថវិកាជូនទៅតាមចំនួននៃសមាជិកបានន័យថា ក្រុមគ្រួសារដែលជាសមាជិកនីមួយៗបង់ប្រាក់វិភាគទាន ១០ ដុល្លារ សម្រាប់បុណ្យសពនីមួយៗក្នុងពេលនេះសមាជិកមានចំនួនប្រមាណ ៦០០នាក់ សមាគមដកយកកំរៃគ្រប់គ្រងចំនួន ៣០ភាគរយ ដូចនេះសមាជិកគ្រួសារសពទទួលបានចំនួនជាង ៤ពាន់ដុល្លារ ដែលប្រាក់នោះត្រូវចំណាយទៅលើក្តារម្ឈូសតម្លៃ២៥០០ដុល្លារយ៉ាងតិចទៅលើកន្លែងបូជាតម្លៃពី៥៥០ដុល្លារ ដល់៥៧៥ដុល្លារទៅលើផ្កា ទៅតាមចំណូលចិត្តរបស់គ្រួសារអស់ប្រមាណជា៣០០ដុល្លារទៀត បូកសរុបទៅអស់ពីប្រមាណ ៣៥០០ដុល្លារ។

សំណួរមួយទៀតស្តីពីកន្លែងធ្វើបុណ្យទានធូបនិមន្តព្រះសង្ឃសូត្រមន្ត អញ្ជើញលោកអាចារ្យមករៀបដឹកពិធី តើនៅលើបន្ទុកអ្នកណា? ព្រះតេជគុណ រដ្ឋ មុនី និងលោក ស៊ិន សុវណ្ណ បញ្ជាក់ថា "ចំពោះកន្លែងធ្វើបុណ្យសព ការរត់លិខិតធ្វើបុណ្យសព ទាន ធូប វត្តព្រះពុទ្ធរង្សីមិនឱ្យមានចេញតម្លៃអ្វីមួយទេ រីឯព្រះសង្ឃ និងអាចារ្យដែលចូលរួមពិធីសូត្រមន្តនានា នៃបុណ្យសពនោះសមាជិកចង់ប្រគេនបច្ច័យក៏ធ្វើបានទៅតាមសទ្ធាជាទម្លាប់ពុទ្ធបរិស័ទ បើមិនប្រគេន ឬជូនបច្ច័យក៏បានដែរ"។ ក៏ប៉ុន្តែនៅលើសំណួរថា "នៅពេលបុណ្យសពមានការចូលបច្ច័យក្នុងពិធីជួយដល់គ្រួសារនៃសព តើវត្តមានយកកំរៃអ្វីទេ?" លោក ស៊ិន សុវណ្ណ ឆ្លើយថា សមាគមឥតមានទទួលខុសត្រូវអ្វីលើប្រាក់នោះទេ គឺប្រគល់ឱ្យក្រុមគ្រួសារទទួលខុសត្រូវយកខ្លួនឯងទាំងអស់ សមាគមមានបទពិសោធន៍ហើយសង្កេតឃើញថា អ្នកចូលបុណ្យខ្មោចយ៉ាងហោចណាស់ក៏បានបីពាន់ដុល្លារ ចំពោះអ្នកមិនសូវមានបងប្អូន តែបុណ្យខ្មោចដែលមានញាតិមិត្តបងប្អូនច្រើនគេចូលបុណ្យដល់ទៅ ៦-៧ពាន់ដុល្លារ ដែលបានទៅគ្រួសារនៃសពទាំងអស់ បន្ថែមទៅលើប្រាក់សមាជិកភាព ។ ព្រះតេជគុណ រដ្ឋ មុនី ឆ្លៀតឱកាសបញ្ជាក់សង្ឃដីកាបន្ថែមថា "វត្តព្រះពុទ្ធរង្សីចង់ឱ្យសហគមន៍ខ្មែរមានទីកន្លែងដ៏ធំទូលំទូលាយ រឹងមាំ សំរាប់ធ្វើបុណ្យសពដោយពុំចាំបាច់ពឹងផ្អែកទៅលើសហគមន៍ណាផ្សេងទៀតទេ គឺតាំងពីចាត់ចែងទៅយកសពទៅសំអាតរៀបចំខ្លួនឱ្យធ្វើលិខិតស្នាមដឹកសព ដោយមិនឱ្យក្រុមគ្រួសារមានកង្វល់អ្វីទាំងអស់ គឺវត្តឥតយកកំរៃអ្វីទេ បើត្រូវចេញកំរៃគឺសម្រាប់ Funeral Home នៅវត្តសូម្បីតែទីកន្លែងក៏វត្តជាអ្នកទទួលចេញដែរ"។ ដើម្បីចូលជាសមាជិក លោក ស៊ិន សុវណ្ណ បញ្ជាក់ថា "លោកអ្នកត្រូវបំពេញសំណុំលិខិតសុំចូលជាសមាជិក មានមេគ្រួសារ និងថ្ងៃខែឆ្នាំកំណើត អាស័យដ្ឋានគ្រួសារ ទូរស័ព្ទ ហើយខាងក្រោមមានចុះឈ្មោះប្រពន្ធ **តទៅទំព័រទី១៥**


# GATEWAY FAMILY DENTAL

NOW OPENED AT GATEWAY CENTER II (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)



**DR. SERENA B. CHUOP**

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 10 years, she has been in private practices providing all aspects of General Dentistry. Dr. Chuop has opened a brand new state of the art dental practice that includes digital x-ray, paperless patient chart system, and brand new dental equipments.




**WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វ៉ែរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

MOST DENTAL INSURANCES ACCEPTED
INCLUDING MASSHEALTH FOR KIDS
FINANCING AVALIABLE
យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន
Masshealth for Kids
យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ
CALL FOR YOUR FREE CONSULTATION
(978) 455-5044

www.gatewayfamilydental.com

# កិច្ចព្រមព្រៀងក្រុងប៉ារីសអនុវត្តន៍នៅកម្ពុជា

***បទសម្ភាសន៍ជាមួយសមាជិកសភាខ្មែររបស់គណបក្សសិទ្ធិមនុស្ស យ៉ែម ប៉ុញ្ញារិទ្ធ (ភាគបន្ត)***

**ដោយ : ពិន សំខុន**


យ៉ែម ប៉ុញ្ញារិទ្ធ

**ខ្មែរប៉ុស្តិ៍ ស.រ.អា :** ដោយឱកាសនេះជាខួបកំណើតកិច្ចព្រមព្រៀងក្រុងប៉ារីសគម្រប់២០ឆ្នាំហើយ តើលោកនឹងគណបក្សសិទ្ធិមនុស្សមើលឃើញការអនុវត្តកិច្ចព្រមព្រៀងនេះនៅកម្ពុជាមានលក្ខណ:ត្រឹមត្រូវប៉ុណ្ណា ?

**យ៉ែម ប៉ុញ្ញារិទ្ធ :** យើងបានដឹងទាំងអស់គ្នារួចមកហើយថា កម្ពុជាបានមកដល់ស្ថានភាពថ្ងៃនេះ ក៏ដោយសារសន្ធិសញ្ញាក្រុងប៉ារីសថ្ងៃ២៣តុលា ឆ្នាំ១៩៩១ ជាខួបឆ្នាំទី២០ ហើយលោកប្រធាន កឹម សុខា និងអញ្ជើញចូលរួមការរៀបចំទទួលខួបឆ្នាំទី២០នេះ នៅទីក្រុងវ៉ា ស៊ិនតោនឌីស៊ី ។ យើងសង្កេតឃើញថា មានចំណុចខ្វះខាតជាច្រើនក្នុងការគោរពសន្ធិសញ្ញាក្រុងប៉ារីសនេះ ឧទាហរណ៍ដូចជា ការមិនទទួលស្គាល់ការចុះហត្ថលេខាក្នុងស្ថានភាពបង្ខិតបង្ខំពេលកម្ពុជាគ្មានឯករាជ្យពិតប្រាកដមាត្រាមួយចំនួនក៏បានថែងពីឯករាជ្យភាពរបស់កម្ពុជា បើមានបញ្ហាអញ្ជើងកម្ពុជាអាចស្នើសហប្រធានបារាំង និងឥណ្ឌូនេស៊ីឱ្យជួយដោះស្រាយ ក៏ប៉ុន្តែរហូតមកដល់បច្ចុប្បន្នហ្នឹងព្រំប្រទល់ដែនក៏មានបញ្ហាចម្រូងចម្រាសបញ្ហាអន្តោប្រវេសន៍ក៏ដូចគ្នាបញ្ហាហត្ថលេខាព្រមព្រៀង មុនខែតុលា ឆ្នាំ១៩៩១ ក៏នៅមានបញ្ហាយើងសង្កេតឃើញថា រដ្ឋាភិបាលខ្មែរយើងពុំបានស្នើឱ្យសើរើទេ។

**ខ្មែរប៉ុស្តិ៍ ស.រ.អា :** តើក្នុងនាមលោកជាសមាជិករដ្ឋសភាខ្មែរលោកមានដែលបានឃើញផែនទីថ្មី ដែលចុះហត្ថលេខាដោយរដ្ឋាភិបាលសភាទាំងពីរ និងព្រះមហាក្សត្រខ្មែរ ដែលរដ្ឋាភិបាលតែងប្រកាសថា មិនធ្វើឱ្យកម្ពុជាបាត់បង់ទឹកដី១ម៉ែត្រក្រឡាណាទេដែរ ឬទេ?

**យ៉ែម ប៉ុញ្ញារិទ្ធ :** មកទល់ថ្ងៃហ្នឹងយើងមិនដែលបានឃើញផែនទីនោះនៅឡើយទេ ក៏ប៉ុន្តែយើងមានចម្ងល់ថា បើមិនមានបាត់ទឹកដីអ្វីទេនោះហេតុអ្វីក៏ខ្លាចមិនបង្កើតគណកម្មាធិការចម្រុះសភាដែលមានគ្រប់វិធានការគណបក្សចូលរួមត្រួតពិនិត្យទៅ ពីព្រោះបញ្ហាព្រំប្រទល់ដែនជាបញ្ហារបស់ជាតិទាំងមូលពុំមែនជារបស់បក្សណាមួយនោះទេ។

**ខ្មែរប៉ុស្តិ៍ ស.រ.អា :** គណបក្សប្រឆាំងទាំងពីរ គឺគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សបាននិយាយពីការបាត់បង់ទឹកដី និងបង្ខិតព្រំដែនជាច្រើនកន្លែង តើនេះជាការគ្រោះថ្នាក់ទេ?

**យ៉ែម ប៉ុញ្ញារិទ្ធ :** នេះជារឿងសំខាន់ ពីព្រោះពលរដ្ឋខ្មែរយើងលោកលើកពីការបាត់បង់ស្រែរបស់គាត់ដែលគាត់ធ្វើពីយូរយារមកហើយ តាមបណ្តោយព្រំដែន ដូច្នេះការបាត់បង់ដីស្រែរបៀបនេះយើងគួរតែទៅពិនិត្យឱ្យបានច្បាស់លាស់មុននឹងសម្រេចបោះបង្គោលព្រំដែន។

**ខ្មែរប៉ុស្តិ៍ ស.រ. អា :** តើមានបញ្ជាក់ថា បាត់បង់ដីស្រែទៅជារបស់យួនដែរ ឬទេ?

**យ៉ែម ប៉ុញ្ញារិទ្ធ :** បានមានបញ្ជាក់អ៊ីចឹងមែន !

**ខ្មែរប៉ុស្តិ៍ ស.រ.អា :** ចុះរដ្ឋាភិបាលគេថាម៉េច ថាអត់មានបាត់ទឹកដីអ៊ីចឹងឬ?

**យ៉ែម ប៉ុញ្ញារិទ្ធ :** ខ្ញុំមិនចង់និយាយជំនួសគណបក្សដ៏ទៃទេ តែបើនិយាយតាមការស្គាល់គ្នានោះ មានការទទួលស្គាល់ថា មានបាត់បង់ដីអ៊ីចឹងមែន។

**ខ្មែរប៉ុស្តិ៍ ស.រ.អា :** បងប្អូនខ្មែរនៅឯនាយសមុទ្រនោះមានកង្វល់ច្រើនចំពោះការបាត់បង់ទឹកដីខ្មែរទៅប្រទេសដ៏ទៃ កង្វល់មួយទៀតចំពោះភាពក្រីក្ររបស់ពលរដ្ឋខ្មែរដែលចេះតែលិចលង់ជ្រៅទៅ តើលោកមានអ្វីបន្ថែមលើកង្វល់ទាំងនោះទេ ?

**យ៉ែម ប៉ុញ្ញារិទ្ធ :** បើតាមការផ្សព្វផ្សាយគេលើកឡើងថា ប្រជាពលរដ្ឋមានប្រាក់ចំណូលប្រចាំឆ្នាំ៧ ឬ៨០០រយដុល្លារគេថាមួយទៀតអំពីភាពក្រីក្របានត្រូវកាត់បន្ថយតែយើងខ្ញុំបានចុះទៅជួបប្រជាពលរាស្ត្រផ្ទាល់តែម្តងយើងឃើញពុំមានការយកចិត្តទុកដាក់ពីការងាររបស់ពលរដ្ឋទេ ហើយក៏គ្មានទីផ្សារសំរាប់ប្រជាពលរដ្ឋអាចលក់ផលិតផលដែលផលិតបានទេដូច្នេះបើគ្មានការងារធ្វើ និងលក់ផលិតផលមិនបានភាពក្រីក្រខ្វះប្រាក់ចំណូលការខ្វះស្បៀងអាហារវាជារឿងប្រចាំថ្ងៃហើយបាទ ! **តទៅទំព័រទី០៧**

COMMUNITY MORTGAGE SERVICES INC.

Mortgage Services

ក្រុមហ៊ុនយើងខ្ញុំមាននិយាយភាសាខ្មែរ ចិន និង វៀតណាម

21 Branch Street #6 (2nd Floor)
Lowell | MA | 01851

Office: (978) 275-6432 ~ Fax: (978) 275-9607

Lic MB4853

"Serving our community with integrity and honesty"



Community Insurance Group, Inc.

ក្រុមហ៊ុនធានារ៉ាប់រង

Home ផ្ទះ | Auto ឡាន | Life ជីវិត | Bussiness កិច្ចការ

21 Branch Street #8 (2nd floor)
Lowell | MA | 01851

Office: (978) 275-9592 ~ Fax: (978) 275-9590



មន្ទីរសុខភាព ART OF WELLNESS CENTER

647 Bainbridge St. Phila PA., 19147 215-305-2238

ទទួលព្យាបាលខ្លួន និងបញ្ហាផ្លូវចិត្តធ្វើទៅតាមទម្លាប់ និងជំនឿរបស់លោកអ្នកដោយប្រើរបៀបបច្ចេកទេសអាស៊ីនិងបច្ចេកវិទ្យាបស្ចឹមប្រទេស ។



ទទួលព្យាបាលគ្រប់វិធី
• ប្រើម្ជុលឥតថ្នាំ • ចាប់សរសៃ • ចិត្តវិទ្យា • យោគ/ភាវនា

TREATMENT TYPE
• Acupuncture • Acupressure • Psychotherapy • Yoga/ Meditation

www.artofwellnesscenter.com

ចំពោះលោកអ្នកមានការលំបាកណាមួយដូចចំណុចខាងក្រោម :

- Weight Management for Adult & Children
- Diabetes
- High Blood Pressure
- High Cholesterol Level Issue
- Pain Management
- Nutrition Consultation (Free)
- Women's Health

- គ្រប់គ្រងទម្ងន់សម្រាប់ចាស់និងក្មេង
- ទឹកនោមផ្អែម
- លើសសម្ពាធឈាម
- លើសកំរិត កូលេសស្តេរ៉ូល
- ឈឺខ្លួនប្រាណគ្រប់កន្លែង
- ពិគ្រោះពីម្ហូបអាហារ (មិនយកកំរៃ)
- សុខភាពស្ត្រី

- Insomnia (Difficulty Sleeping)
- Feeling Tired & Weak
- Stress /Anxiety
- Depression
- Family Issues
- Addiction Issues
- Anger Management

- ដេកមិនលក់
- អស់កម្លាំង មិនស្រួលខ្លួន
- ភាពតានតឹង/ការថប់អារម្មណ៍
- ធ្លាក់ទឹកចិត្ត
- មានវិបត្តិក្នុងគ្រួសារ
- ការញៀន និងអ្វីមួយ
- មានកំហឹងច្រើន

យើងទទួលយក AETNA នឹង UNITED HEALTHCARE CIGNA

ទស្សនៈនយោបាយ

# សូមជនជាតិខ្មែរក្រៅប្រទេសត្រូវតែគិតគូរដល់ជាតិសាសន៍មាតុប្រទេសយើងផង



ដោយ : ម៉ម យីន

នៅលើពិភពលោកមានជាតិសាសន៍ច្រើនណាស់ បានអាស្រ័យរស់នៅប្រកបការងារចិញ្ចឹមជីវិតឱ្យបានសេចក្ដីសុខសប្បាយរីករាយថ្កើងរុងរឿងពេញលក្ខណៈជាមនុស្សជាតិដូចៗគ្នា។

នៅក្នុងសហរដ្ឋអាមេរិក កាលពីសម័យមុនឆ្នាំ១៩៧៥ មានជនជាតិខ្មែរតិចតួច ដែលបានចូលមករស់នៅជាអចិន្ត្រៃយ៍ក្រៅពីក្រុមគ្រួសាររបស់អង្គទូត ដែលជាតំណាងឱ្យប្រទេសខ្មែរ ត្រូវតែមកបំពេញបេសកកម្ម ទំនាក់ទំនងគ្នាជាសម្ព័ន្ធមិត្តក្នុងកិច្ចការនយោបាយ សេដ្ឋកិច្ចជាដើម ហើយនឹងមានមន្ត្រីគ្រប់ស្ថាប័នមួយចំនួនបានមកហ្វឹកហ្វឺនការងារផ្នែករដ្ឋបាល និងបច្ចេកទេសរួមទាំងយុវនិស្សិតស្រីប្រុស ដែលបានទទួលអាហារូបករណ៍របស់រដ្ឋាភិបាលខ្មែរ ឬសហរដ្ឋអាមេរិកក៏បានមកសិក្សាក្រេបជញ្ជក់យកចំណេះវិជ្ជាក្នុងមួយរយៈពេលសិក្សា ។ ដូចជារូបខ្ញុំឈ្មោះ ម៉ម យីន នេះ ក្នុងឋានៈខ្ញុំជាគ្រូបង្រៀនបច្ចេកទេស ខ្ញុំបានមកបំពេញវិជ្ជាគរុកោសល្យរយៈពេលមួយឆ្នាំនៅ ស.រ .អា និងកាណាដានាឆ្នាំ១៩៥៨-៥៩។

លុះដល់ឆ្នាំ១៩៧៥ ក៏មានមន្ត្រី ទាំងស៊ីវិល ទាំងយោធាមួយចំនួនបានមកហ្វឹកហ្វឺនសិក្សា ស្រាប់តែប្រទេសខ្មែរត្រូវបានធ្លាក់ទៅនៅក្រោមអំណាចពួកកុម្មុយនីស្តខ្មែរក្រហម ក៏បានបង្ខិតបង្ខំចិត្តសុំសិទ្ធិជ្រកកោនរស់នៅរហូតមកដល់សព្វថ្ងៃនេះដែរ ។

ប៉ុន្តែនៅក្នុងឆ្នាំ១៩៧៩ មានព្រឹត្តិការណ៍ថ្មីមួយទៀតបានលើកឡើង ដោយកងទ័ពយួនកុម្មុយនីស្ត២០ម៉ឺននាក់ បានវាយលុកលុយផ្ដួលរំលំរបបខ្មែរក្រហមប្រល័យពូជសាសន៍តាំងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ ទើបបណ្ដាលឱ្យជនជាតិខ្មែរនាំគ្នារត់ចាកចេញមកកាន់ប្រទេសទីពលោកសេរីមានដូចជា ស.រ.អា បារាំង កាណាដា អូស្ត្រាលី ញ៉ូវហ្សេឡិន ជប៉ុន ជាដើម ដោយសារតែប្រទេសទាំងនេះ គេមានសន្ដានចិត្តសប្បុរស មនុស្សធម៌ជួយសង្គ្រោះដល់ជីវិតជនជាតិខ្មែរនាសម័យគ្រួតត្រាដោយរបបកុម្មុយនីស្តខ្មែរក្រហមផ្ដាច់ការនោះ ។ គេសង្កេតឃើញ ស.រ.អា ជាប្រទេសធំជាងគេដែលបានយល់ព្រមទទួលយកជនភៀសខ្លួនខ្មែរច្រើនជាងគេដោយឥតរើសមុខ បើគិតជាចំនួនមានប្រមាណជិត១លាននាក់ ដែលបានមកតាំងទីលំនៅថ្មីជាអចិន្ត្រៃយ៍នៅលើទឹកដីថ្មី ស.រ.អា ទាំងមូល។

គួរឱ្យស្រណោះស្រណោក រំជួលរំជើបរំភើបនៅក្នុងដួងចិត្តខ្លាំងណាស់ មិននឹកស្មានថាខ្លួនមានភព្វវាសនាបានគង់វង្សជីវិត ហើយបានមករស់នៅលើទឹកដីថ្មីមួយដែលមានមេដឹកនាំប្រទេស មានធម៌សប្បុរស មនុស្សធម៌អាណិតអាសូរស្រឡាញ់ជនជាតិខ្មែរយើង ដែលជាមនុស្សឥតមានតម្លៃអ្វីសោះ ចំណេះវិជ្ជាក៏គ្មានលុយកាក់ទ្រព្យសម្បត្តិក៏គ្មាន សុខភាពកាយចិត្តសម្បទាក៏ទ្រុឌទ្រោមទន់ខ្សោយ ជាមនុស្សមិនគួរឱ្យគេរាប់រកទេ ផ្ទុយទៅវិញ ស.រ.អា ដែលជាប្រទេសមហាអំណាចមានអរិយធម៌ខ្ពង់ខ្ពស់ណាស់មានសប្បុរសធម៌ និងមនុស្សធម៌ខ្ពង់ខ្ពស់ណាស់ បានសម្រេចយល់ព្រមទទួលយកជនជាតិខ្មែរដ៏មហាអភព្វទាំងនេះឱ្យបានមករស់នៅកសាងជីវិតថ្មី រួចហើយជួយទំនុកបំរុងបីបាច់ថែរក្សា ឧបត្ថម្ភផ្គត់ផ្គង់គ្រប់បែបយ៉ាងស្មើមុខគ្នាដូចគ្នាជនជាតិអាមេរិកកាំងជាម្ចាស់ប្រទេសនោះដែរ ។

ដោយទប់ចិត្តមិនបាន ពេលរូបខ្ញុំកំពុងតែសរសេរអត្ថបទនេះ ដួងចិត្តខ្ញុំក៏កំពុងតែរំជើបរំជួលអួលអាក់ស្មើរស្រក់ទឹកភ្នែកដែរ បងប្អូនខ្មែរអើយ ពិតមែនតែរូបខ្ញុំ និងគ្រួសារមានគ្នា១០នាក់ បានមកដល់ទឹកដីដ៏បវរនេះ ដូចគ្នាបងប្អូនខ្មែរ ដែលបានមកដល់ពីឆ្នាំ៧៥៧៩ - ៨១ នៅលើទឹកដីថ្មីនៃប្រទេសមហាអំណាចធំជាងគេមួយ ដែលមានមេដឹកនាំប្រកបដោយព្រហ្មវិហារធម៌ទាំង៤ គឺមេត្តា ករុណា មុទិតា និងឧបេក្ខា ព្រមទាំងមានគតិយុត្តិធម៌ ប្រាស់ចាកដាច់ស្រឡះពីអគតិទាំង៤ គឺឆន្ទាគតិ លំអៀងព្រោះស្រឡាញ់ ទោសាគតិ លំអៀងព្រោះស្អប់ មោហាគតិ លំអៀងព្រោះល្ងង់ខ្លៅ និងភយាគតិ លំអៀងព្រោះភ័យខ្លាច ។ យើងទាំងអស់គ្នាជាជនជាតិខ្មែរ សូមសំដែងសេចក្ដីអំណរអរគុណជាអតិបរមាបំផុតដល់មេដឹកនាំ និងបណ្ដាប្រជាពលរដ្ឋអាមេរិកកាំង និងសូមព្រះប្រទានពរ បវរជោគជ័យមហាប្រសើរជានិរន្តរ៍ ។

ក្រោយពីបងប្អូនរួមជាតិខ្មែរ បានមករស់នៅកសាងជីវិតថ្មី លើទឹកដីថ្មី ពេលនេះប្រៀបបានដូចជារុក្ខជាតិដ៏ស្រស់បំព្រង មានស្លឹកពណ៌ខៀវស្រងាត់ដុះនៅជិតមាត់ទឹកដ៏ថ្លាឆ្វង់ បញ្ចេញផលផ្កាផ្លែបានគ្រប់រដូវកាល មានរស់ជាតិឆ្ងាញ់ពិសារណាស់សម្រាប់យើង និងគ្រួសារទាំងអស់ ។ រដ្ឋាភិបាលស.រ.អា បានផ្ដល់ការចិញ្ចឹមបីបាច់ថែរក្សា បានផ្ដល់លុយកាក់ ម្ហូបអាហារ ផ្ដល់សំលៀកបំពាក់ ប្រដាប់ប្រើប្រាស់ មានពេទ្យព្យាបាលជម្ងឺដោយឥតបង់លុយ បុត្រាបុត្រីបានទៅសាលារៀន យុវជនយុវនារីមានមុខរបរប្រកបការងារ មានទីលំនៅស្អាតសមរម្យ មានរថយន្តប្រើប្រាស់គ្រប់ៗគ្នា ។ គួរឱ្យជនជាតិខ្មែរយើងម្នាក់ៗនាំគ្នាកែប្រែផ្លាស់ប្ដូរចិត្តគំនិតរបស់យើង ដែលមានចិត្តគំនិតខ្ចីដូចកាលរស់នៅក្នុងប្រទេសខ្មែរនោះទៀតទៅ ។ យើងបានឃើញផ្ទាល់នឹងភ្នែក បានឮផ្ទាល់នឹងត្រចៀក ឃើញនូវទង្វើរបស់លោកប្រធានាធិបតី អស់លោកមន្ត្រីគ្រប់ស្ថាប័ន គ្រប់តំណែងអាមេរិកកាំងយ៉ាងច្បាស់ជាក់ស្ដែងឃើញល្អប្រសើរ គេស្រឡាញ់មនុស្សជាតិដូចគ្នា ឥតរើសអើងប្រកាន់ពូជសាសន៍ គេគោរពគោលការណ៍លិទ្ធិប្រជាធិបតេយ្យសេរី គេផ្ដល់សិទ្ធិសេរីភាពឱ្យមនុស្ស សូមបងប្អូនកែប្រែផ្លាស់ប្ដូរចិត្តគំនិតឱ្យបានសមស្របទៅនឹងទំហំនៃទង្វើប្រព្រឹត្តល្អប្រពៃជាគំរូរបស់ប្រទេស និងជនជាតិអាមេរិកកាំង ចំពោះយើងទាំងអស់គ្នានោះផងទៅដែរ ។

សំខាន់បំផុត ដូចជាជនជាតិ **តទៅទំព័រទី១៨**




# ចូរធ្វើចលនា!

មួយភាគបីនៃក្មេងៗ ប្រឈមមុខចំពោះបញ្ហាសុខភាពធ្ងន់ធ្ងរខ្លាំងណាស់ ដោយព្រោះតែធាត់ពេក ។ យើងអាចជួយកូនរបស់អ្នកឲ្យជៀសវៀង ជាមួយនឹង :

- ការចូលជាសមាជិកនៅមណ្ឌលហាត់ប្រាណ
- អត្ថប្រយោជន៍ Weight Watchers® របស់យើង (សំរាប់ក្មេងៗ អាយុ 10+)
- ការប្រឹក្សាខាងអាហារមានជីវជាតិ

CHIP បាននាំមកជូនអ្នកដោយ KidzPartners មានផ្ដល់ការធានារ៉ាប់រងសុខភាពដោយឥតគិតថ្លៃ ឬថោកថ្លៃ សំរាប់ក្មេងៗ និងក្មេង ជំទង់ៗ ដែលគ្មានការធានារ៉ាប់រង ។ ថែមទាំងអត្ថប្រយោជន៍ដែល អាចនាំឲ្យមានសុខភាពល្អអស់មួយជីវិត ។

ចូរដាក់ពាក្យសុំនៅថ្ងៃនេះ!
**1-888-888-1211**
TTY 1-877-454-8477

Pennsylvania's Children's Health Insurance Program
យើងរ៉ាប់រងក្មេងៗទាំងអស់។

KidzPARTNERS
គំរោងសំរាប់ក្មេងៗរបស់ HEALTH PARTNERS

www.chipcoverspakids.com

www.kidzpartners.com

តមកទំព័រទី ៤

# កិច្ចព្រមព្រៀង...

**ខ្មែរប៉ុស្តិ៍ ស.រ.អា :** សញ្ញាដែលបញ្ជាក់ថា ពលរដ្ឋមានជីវភាពកើនឡើង គឺនៅលើផ្ទះសម្បែងមានទឹកអគ្គិសនី មានបន្ទប់ទឹក បង្គន់ បន្ទប់ដេកសមរម្យ តើជនបទខ្មែរមានកើនចំនួនរបស់ទាំងនោះនៅផ្ទះហើយ ឬនៅ?

**យ៉ែម ប៉ុញ្ញារិទ្ធ :** ខ្ញុំសង្កេតឃើញថា នៅមានតិចតួចនៅឡើយ ដូចយើងដឹងហើយថា មនុស្សដើម្បីរស់ឱ្យសមសួនជាមនុស្សត្រូវការ៥យ៉ាង ១.សំលៀកបំពាក់ចំណីអាហារ ២.ផ្ទះសម្បែង ៣.ថ្នាំសង្កូវ ៤.ការសិក្សារៀនសូត្រ ៥.ការងារយើងពិនិត្យឃើញថា បងប្អូនខ្មែរយើងពុំបានទទួលនៅឡើយទេ ទាំងនេះធ្វើឱ្យយើងចាត់ទុកថា ប្រជា-ពលរដ្ឋយើងនៅក្រីក្រ និងរងគ្រោះខ្លាំងហើយច្រើននៅឡើយ។

**ខ្មែរប៉ុស្តិ៍ ស.រ.អា :** តើស្ថិតិដែលនិយាយពីមនុស្សដែលនៅក្រោមបន្ទាត់ក្រីក្រមានប៉ុន្មានភាគ ?

**យ៉ែម ប៉ុញ្ញារិទ្ធ :** គេនិយាយថា ២៧ភាគរយប្រ-ជាពលរដ្ឋខ្មែរ ៩០ភាគរយជាកសិករកម្មករ គឺជាអ្នករងគ្រោះជាងគេ ហើយគេយកចំនួនអ្នកទាំងនោះមកគិតជាភាគរយដែលគេហៅថា ផលសរុបប្រចាំឆ្នាំថា ប្រជាពលរដ្ឋរកប្រាក់ចំណូលបាន ៧ ទៅ ៨០០ដុល្លារ ក្នុង១ឆ្នាំនោះយើងមិនអាចធ្វើដូច្នោះបានទេ គេអាចវាស់ស្ទង់ក្នុងផលសរុបក្នុងស្រុករបស់ពលរដ្ឋនីមួយៗបានវាទាល់តែមានកំណត់ប្រាក់ចំណូលប្រចាំខែជាអប្បរមាឱ្យបានពិតប្រាកដសិន ឯនៅកម្ពុជាប្រាក់ចំណូល១ប្រចាំខែរបស់មន្ត្រីរាជការកម្មករ កសិករ មិនទាន់មានកំណត់នៅឡើយទេ ហើយឧទាហរណ៍ដែលថា យកប្រាក់ចំណូលរបស់អ្នកឧកញ៉ាចំនួនរាប់លានដុល្លារមកបូកជាមួយប្រាក់ចំណូលប្រជាពលរដ្ឋដែលរកសម្រាប់រស់ពី១ថ្ងៃទៅ១ថ្ងៃ ហើយចែកយកមធ្យមភាគនោះមិនត្រឹមត្រូវទេ ពីព្រោះគម្លាតរវាងអ្នកមាន និងអ្នកក្រខ្មែរនោះមានច្រើនមែនទែន រីឯនៅប្រទេសជឿនលឿនពិតប្រាកដនោះ គម្លាតនោះមានតិចតួច ដូច្នេះតួលេខចេញដោយរដ្ឋាភិបាលនេះ ពុំបានធ្វើឱ្យយើងមានជំនឿយកទៅវាយតម្លៃបាននោះទេ។

**ខ្មែរប៉ុស្តិ៍ ស.រ.អា :** នៅចុងបញ្ចប់នៃបទសម្ភាសន៍នេះខ្ញុំចង់ដឹងថា នៅក្នុងការបោះឆ្នោតសភាខាងមុខ តើនឹងមានគណបក្សចំនួនប៉ុន្មានចូលរួមប្រកួត?

**យ៉ែម ប៉ុញ្ញារិទ្ធ :** រហូតមកដល់ពេលនេះ តាមការកត់សម្គាល់របស់ខ្ញុំសង្កេតឃើញថា នឹងមានគណបក្សដែលមានអាសនៈនៅក្នុងសភានឹងចូលរួម មានគណបក្សសិទ្ធិមនុស្ស គណបក្ស សម រង្ស៊ី គណបក្សនរោត្តម រណឫទ្ធិ គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សប្រជាជន រីឯគណបក្សដទៃទៀតអាចនឹងមានវត្តមានដែរ ដែលគេបង្កើតឡើងគ្រាន់តែមានឈ្មោះបោះឆ្នោត ហើយក្រោយពេលបោះឆ្នោតរកទីតាំងមិនឃើញ ហើយគ្មានសកម្មភាពអ្វីទាំងអស់។

**ខ្មែរប៉ុស្តិ៍ ស.រ.អា :** សូមអរគុណលោក យ៉ែម ប៉ុញ្ញារិទ្ធ ដែលបានឆ្លៀតពេលមកផ្ដល់ព័ត៌មានជូនបងប្អូនខ្មែរនៅស.រ.អា នេះ៕


ក្រុមហ៊ុនទេសចរណ៍
ភ្នំពេញអន្តរជាតិ
Phnom Penh International Travel Services

21 Branch St., Ste #1
Lowell, MA 01851
Tell: 978-970-5999
Fax: 978-970-5599

109 Lafayette St. #C-5
New York, NY 10001
Tell: 212-219-2299
Fax: 212-219-9930

- លក់សំបុត្រយន្តហោះសម្រាប់ក្នុង និងក្រៅប្រទេស
- ធ្វើលិខិតធានា ប្ដី ប្រពន្ធ ឬគូដណ្ដឹងពីស្រុកខ្មែរ
- ធ្វើលិខិតសុំច្បាប់ចេញចូល -Re-Entry Permit
- ពន្យា Passport ខ្មែរ Laisser Passer
- ធ្វើទិដ្ឋាការ Visa ទៅអាស៊ី
- ធ្វើលិខិតសុំ Green Card I-94 Work Permit
- បំពេញសុំចូលសញ្ជាតិ
- ថតរូបសម្រាប់ចូលសញ្ជាតិ និងទទួលផ្ញើប្រាក់ទៅស្រុកខ្មែរគ្រប់ប្រទេស
- លក់ Money Order និងបោះត្រា Nortary Public




978-970-5999



KHMER POST USA, LLC
East Coast Publication

**Pin Samkhon,**
*Publisher & Editor-in-Chief*
Email: pinsamkhon@gmail.com
*Staff Writers:* **Loeum Im, Audria Chea,**

*Contributed Writers:*
**Mam Yin, Kim Phien, Lanica Angpak, &**
KhmerPostLowell@gmail.com

**Soben Pin**
*Marketing Director*
KhmerPostUSA@gmail.com
**267-253-3947**
**Sam Khoeun**
*Sales Consultant*
**(781) 244-0522**

*Design Staffs:*
**Leang Heng & Mong Meng**

~~~~~

KhmerPost USA, LLC is an independent newpaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local, community, and national news; and give an insight into Cambodia & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Pennsylvanian & Massachusett.

~~~~~

Semimonthly edition subscription is available within the U.S. & Canada at $60.00 and 70 Euros in Europe per year. Money order or check is accepted and made payable to:
KhmerPost USA, LLC
438 LINDLEY AVE.
Philadelphia, PA 19120

~~~

The Khmer Post has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009



ពេទ្យធ្មេញសំរាប់គ្រួសារ Caring Dental For ALL Ages




FREE
Teeth Whitening
New patients get a complimentary teeth whitening kit with completed exam, cleaning & x-rays at regular price. Cannot be combined with any other offers. Expires 10/30/11

"EXCLUSIVE OFFER"
$55.00
Limited Time New Patient Special
(Regular Discount $55.99 a $250 Value)
Present coupon for discount. Includes exam, bite-wing x-ray & cleaning. Cannot be combined with other offers or insurance. Expires 10/30/11

COMPLETE ផ្ដល់គ្រប់សេវាកម្ម
Services

- Cosmetic Dentistry • ត្រួតពិនិត្យទៀតទាត់ពេល
- Cosmetic Fillings • សំអាតធ្មេញ
- Crowns & Bridges • ជំងឺចង្កោញធ្មេញ
- Dentures • ដកសរសៃធ្មេញ
- Extractions • ស្រោប-តម្រឹម និងប៉ះធ្មេញ
- Implant Crowns • ធ្វើធ្មេញឱ្យស
- Root Canal Therapy • បំពេញធ្មេញប្រហោង
- • ដកធ្មេញ

Most Forms of Insurance & Payment
ACCEPTED ទទួលគ្រប់ អ៊ិនស៊ូរិន
MassHealth • Cigna • Aetna
Amex • Discover • Visa • Mastercard

Convenient LOCATION
Next to Bank of America on Chelmsford Street



យើងមានអ្នកនិយាយភាសាខ្មែរ អង់គ្លេស ស្បាញ៉ុល និងវៀតណាម សូមទូរស័ព្ទ 978-455-4039 ដើម្បីណាត់ជួបនៅថ្ងៃនេះ

724 Chelmsford Street • Lowell, MA • 978-455-4039
www.BrightSmiles-Dental.com
~~~

# ប្រវត្តិរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ រ.ជ.រ.ប.ខ លោកតា ស៊ីន សាន



**ដោយ : ម៉ម យឹន**



●●●ទោះបីជាត្រូវប្រើពេលវេលាត្រូវចំណាយលុយកាក់ និងចំណាយអាយុជីវិតមនុស្សអស់ប៉ុន្មានក៏ត្រូវតែធ្វើឱ្យបានសម្រេចជោគជ័យដែរ ។

ដោយសារគម្រោងផែនការនេះហើយបានជាប្រទេសយួនត្រូវតែប្រើគ្រប់យុទ្ធវិធីទាំងអស់ដែលអាចធ្វើបាន មានវិធីក្ដៅដោយប្រើកលល្បិចយកខ្មែរឱ្យសម្លាប់ជនជាតិខ្មែរគ្នាឯង ជាពិសេសត្រូវសម្លាប់មន្ត្រីបុគ្គលិកសំខាន់ៗបញ្ញាវន្តគ្រប់ជាន់ថ្នាក់ មេទ័ពសំខាន់គ្រប់អង្គភាពកងទ័ពជាក់ស្ដែងនៅក្នុងសម័យខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧០ ។ បន្ទាប់មកអង្គការបក្សប្រជាជនបដិវត្តន៍យួន បានបំបែកបក្សប្រជាជនបដិវត្តន៍ខ្មែរជាពីរក្រុម ដោយបញ្ជាឱ្យក្រុមមួយជាអ្នកកាប់សម្លាប់ប្រជាពលរដ្ឋខ្មែរ លុះដឹងថាសម្លាប់បានចំនួនច្រើនល្មមធ្វើឱ្យកម្លាំងថាមពលខ្មែរត្រូវថយចុះខ្សោយគ្រប់វិស័យហើយ ទើបបញ្ជាឱ្យក្រុមមួយទៀតធ្វើជារត់ចេញទៅពឹងកងទ័ពយួនក្រហមឱ្យលើកទ័ពចូលមកវាយលុកលុយប្រទេសខ្មែរដោយយកលេសថា មកជួយរំដោះសង្គ្រោះជីវិតខ្មែរ ឱ្យរួចផុតពីការកាប់សម្លាប់របស់ក្រុមកម្ពុជាប្រជាធិបតេយ្យ ។

នេះជាកលល្បិចមួយ ដែលប្រទេសយួនក្រហមយល់ថា ជាយុទ្ធវិធីល្អវិសេសសំរាប់យកជោគជ័យ ហើយត្រូវបានក្រុមដែលកងទ័ពយួនក្រហមបានដង្ហែរដោយកងទ័ពយួនចំនួន ២សែននាក់ (២០០,០០០)ឱ្យមកកាន់អំណាចដឹកនាំប្រទេសខ្មែរ ។

ក្រោយពីបានត្រូវកងទ័ពយួនក្រហមតែងតាំងរួចស្រេចហើយ **តទៅលេខក្រោយ**

# ពិពណ៌សុខភាពក្នុងសហគមន៍ខ្មែរ

**ដោយ : ខ្មែរប៉ុស្តិ៍**

ប្រជាពលរដ្ឋខ្មែរប្រមាណ ៣០០នាក់ បានមកទទួលសេវាពិនិត្យសុខភាព ដោយក្រុមអ្នកជំនាញការខាង "អេប៉ាតាយតិះប៊ី" ខាងធ្មេញ ខាងជម្ងឺផ្លូវចិត្ត... ។ល។ នៅបរិវេណវត្តព្រះពុទ្ធរង្សី កាលពីថ្ងៃសៅរ៍២២ តុលា ឆ្នាំ២០១១ កន្លងទៅនេះ ។

"ជម្ងឺនេះអាចការពារកុំឱ្យកើតបាន តែបើមិនធ្វើអ្វីទេ នោះវាអាចធ្វើឱ្យខូចសុខភាពជាខ្លាំង ដូចជាជម្ងឺរលាកថ្លើមរ៉ាំរ៉ៃ ជម្ងឺ Cirrhoris ឬមហារីកថ្លើម"។ អ្នកស្រីធ្វើសេចក្ដីបញ្ចប់ថា "គេពន្យល់ថា បុរសខ្មែរដែលមិនថែខ្លួនច្រើនស្លាប់នៅវ័យក្មេង ហើយបន្សល់នូវគ្រួសារថ្មីថ្មោងពីក្រោយខ្នង"។





អ្នកស្រី វ៉ង ស៊ន នាយិកាសហគមន៍ខ្មែរបានផ្សព្វផ្សាយថា "បងប្អូនខ្មែរគួរតែទៅឱ្យពេទ្យពិនិត្យឆែករកជម្ងឺ "អេប៉ាតាយតិះ B" ដែលសម្បូរណ៍ឈឺនៅក្នុងចំណោមប្រជាពលរដ្ឋខ្មែរលើសគេឯងរហូតដល់ទៅ ១០ដង គឺក្នុង ១០នាក់ មានខ្មែរម្នាក់មានជម្ងឺនេះហើយ " អ្នកស្រីបន្តទៀតថា



លោក អ៊ូ កៅ



អ្នកស្រី វ៉ង ស៊ន (សណ្ដោប្រញ)

ពិពណ៌សុខភាពលើកនេះរៀបចំដោយសមាគមខ្មែរ សមាគមព្រឹទ្ធាចារ្យ សមាគម OPA និងវត្តព្រះពុទ្ធរង្សី។

លោក អ៊ូ កៅ រីករាយនឹងឃើញមនុស្សម្នាចូលរួមច្រើនយ៉ាងនេះក៏ឧទានថា "ខ្ញុំចង់ឃើញមជ្ឈមណ្ឌលសំរាប់ជួយមនុស្សចាស់ខ្មែរមួយ កើតឡើងនៅហ្វីឡាដែលហ្វៀនេះ"៕


ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ អង្គរ

(Since 1991)

ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ-អង្គរ

Angkor International Travel Agency



World Wide Travel & Tour Service
Cambodia - Vietnam - Laos - Thailand

ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ សេវាអន្តោប្រវេសន៍
សេវាលិខិតឆ្លងដែន កក់សណ្ឋាគារ ឬជួលឡាន

**USA**
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
angkortravelphilly@yahoo.com

**Cambodia Office: Victory Travel (Skin Belle)**
No 57B, Eo Street 205 Touls Svay Prey 2.
Phnom Penh, Cambodia.
Ms. Chenda: 023-221069 * 012-851575
Or Mr. Sin Po: 012 429407 * 011-541111.

SERVING SINGAPOR, EVA AIR,CHINA, ASIANA KOREAN AILINES



ភោជនីយដ្ឋាន ណាម វាង (ភ្នំពេញ)

*Nam Vang Restaurant*

**571 Unit#1 Adams Svenue. Philadelphia, PA 19120**
**(inside Hong Kong Market) (215) 742-9488**





រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុក
គ្រប់សេជាតិផ្លែឈើ ដូចជា:
ធុរេន ឬ អាវូកាដូ ហើយជាពិសេស
មានទឹកអំពៅស្រស់ៗ



១_មុខជំនាញខាងម្ហូបខ្មែរ យ៉ាងចំណាន ដូចជា :
-គុយទាវភ្នំពេញ
-គុយទាវ ឬមី-ខគោ
-មីកន្ទាំង ឆាសាច់គោ
-មីកន្ទាំងឆាគ្រឿងសមុទ្រ
-បាយឆាគ្រប់មុខ
-សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

២_មុខជំនាញម្ហូបវៀតណាម ឈ្ងុយឆ្ងាញ់ ដូចជា :
-នំបញ្ចុកទឹកត្រីពិសេស
-នំប៉័ងបាតេ ឬសាច់គោអាំង
-ខគោ នំប៉័ង ឬ មី និងគុយទាវ
-បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង

**Open 7 days a week from 9a.m-9p.m**
**បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច**

# Yoo's Auto Service and Collision

យូ បំរើសេវារថយន្ត
នឹងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច



FREE ESTIMATES

យើងអាចជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក ឱ្យបានប្រសើរបំផុត ដើម្បីសុវត្ថិភាពលោកអ្នក មិនឱ្យខុសចិត្តឡើយ ។

**ផ្នែកជាងម៉ាស៊ីន**

- Check Engine Light Diagnostic
- Electronic Wheel Alignment
- Certified Enhanced Emission
- Inspection & Repairs
- Muffler & More

**ផ្នែកជួសជុលតួរថយន្ត**

- Expert Body Work
- Fender & Paint Work
- Frame Straightening
- Insurance Specialists




189 W. Duncannon Ave. Phila., PA 19120

ទូរស័ព្ទរក SAM 215-457-7777 ឬ 215-457-7779, Fax-215-457-7475



# ការិយាល័យវេជ្ជបណ្ឌិត

ខេរិន : (267) 210 8880



ក្រុមហ៊ុនយើងមានបទពិសោធន៍ ១០ឆ្នាំក្នុងការព្យាបាល :

| | |
|---|---|
| Slip & Fall | រអិល និងដួល |
| Auto Accident | គ្រោះថ្នាក់រថយន្ត |
| Back Pain | ឈឺខ្នង |
| Headache | ឈឺក្បាល |
| Neck Pain | ឈឺកញ្ចឹងក |



- មានអ្នកបកប្រែ និយាយភាសាខ្មែរ, ខេរិន TeL: (267) 210 8880
- មានការណែនាំជូន មេធាវី ដែលមានបទពិសោធន៍ច្រើនឆ្នាំ

**South Office:** 215-776-6215
PAIN & INJURY
CHIROPRACTIC CENTER
1100 Washington Ave., Lot C, Unit #C2
Philadelphia, PA 19147
Tel. 215-468-7256

**North Office:** 267-408-6150
VN Chiropractic Center
5416 N. 5th St.
Philadelphia, PA 19120
Tel. 215-324-1400



# ទីកន្លែងល្អសម្រាប់បើក ភោជនីយដ្ឋានខ្មែរ ចិន ឬវៀតណាម!

Right Here




**OPEN CAMBODIAN, CHINESE OR VIETNAMESE RESTAURANT**

ONLY 5 MINUTES AWAY FROM HONG KONG SUPERMARKET
EASY FOR CAMBODIAN, VIETNAMESE, AND CHINESE TO COME HERE





-នៅជាប់គ្នានឹងហាងកូរ៉េដែលល្បីឈ្មោះធ្វើពីផ្សារហុងកុងតែ៥នាទីទេ និងមកពីនេះ ហើយទីនេះសំបូរទៅដោយជនជាតិ ចិន វៀតណាម និងខ្មែររស់នៅ។
-មានកន្លែងចតរថយន្តបាន ៧៥ ហើយមានអាជ្ញាប័ណ្ណសម្រាប់បើកភោជនីយដ្ឋានរួចជាស្រេច កន្លែងនោះពីមុនជាហាងគុយទាវទំហំ២,៥០០ស្កែហ្វីត

JUST NEXT TO FAMOUS KOEREAN RESTAURANT
75 CARS PARKING LOT
HERE ARE ALREADY RESTAURANT PERMIT AND ZONING
IT WAS FORMERLY NOODLE HOUSE
2,500 SQUARE FEETS

*Mr Peter Han* **215.668-1666**



# ហាងមាសខ្មែរអង្គរ

**Khmer-Angkor Jewelry** 金美成珠寶行

Since 1983 Certified Diamonds & Diamond Jewelry

600 Washington Avenue. Unit 12B. Philadelphia, PA 19147
Tel. 215-599-2222 Fax. 215-599-2223



18K & 24K Gold, Platinum Jewelry & Watches
GIA Graduate Gemologist on Staff
Authorized RADO & LONGINES Dealer
Repairs Done on Premises

Open
Tuesday-Sunday
10:30AM-6:30PM
Closed Monday

# ហាងមាសរស្មី



**SUNSHINE JEWELRY, INC.**
**215-271-2950**

Certified Diamonds & Golds (24K & 18K)
Men & Women Jewelries & Watches
Custom Design & Repairs on Premise
15 Years in Services & Growing Strong







702 Washington Ave. Phila., PA 19147
www.sunshinejewelryonline.com

# NEW CHINA PEARL

DIM SUM & DINNER EVERYDAY

288 Mishawum Rd., Woburn, MA 01801
Phone:(781) 932-0031/Fax: (781) 932-0346
www.NewChinaPearl.com
From Boston 95 South; Exit 37B, from Lowell 93 South; Exist 37B, from RT-128; Exit 36.



ភោជនីយដ្ឋាន "ញូចាណាភើល" សូមអញ្ជើញលោកអ្នក និងក្រុមគ្រួសារមករីករាយជាមួយម្ហូបអាហារមកពីហុងកុង និងប្រទេសអាស៊ីនានាជុំវិញ ។ យើងមានសាលពិធីសាន្តសំរាប់ពិធីការ ឬរាត្រីជួបជុំគ្នាមានបា និងខារ៉ាអូខេទៀតផង កន្លែងចតឡានមិនយកថ្លៃ ហើយមាន

Ballrooms for Wedding & Party
មានឆាករាំសំរាប់ពិធីការ ឬប្រជុំកំសាន្ត

ZAGAT RATED — Very Good to Excellence Food, Boston Restaurants 2011/2012

**LIVE FRESH SEAFOOD**
-SPECIAL LIMITED OF TIME $20.00 TWIN LOBSTER
-SAME AS CHINA TOWN FOOD AND CHIEFS.

**BUSINESS HOURS:** Mon - Wed 11 a.m. - 10 a.m./Thurs. & Fri. 11 a.m. - 12 a.m
Sat. 10 a.m. - 12 a.m / Sun.10 a.m. - 10 p.m.
Delivery Hours 11 a.m. - 9 p.m. min. $15 order plus $2 delivery.



# ភោជនីយដ្ឋាន ឆាយណាស្តារ

*China Star*

មានម្ហូបចិន
ម្ហូបប៉ូលីណេស៊ី
ម្ហូបចិនកង់តុង
ម្ហូបម៉ង់ដារិន

Chinese -Polynesian -Cantonese -Mandarin
369 Broadway St., Lowell, MA 01854
Tel: 978-454-7578, 978-454-7507

Open Daily: Sun. to Thurs. 11:00 AM to 1:00 AM
Fri. and Sat. 11:00 AM to 3:00 AM





យើងអាចយកម្ហូបទៅដល់ផ្ទះបាន
We Deliver All Day: 11:30 AM to 1:00 AM Available to most areas. Min. $10.00 Delivery Charge $2

**$16.95**

បង្កងឆាខ្ញី និងខ្ទឹមពិសេស
SPECIAL 2 Lobsters w/ Scallion & Ginger

# លោក កឹម សុខា បក្សកាន់អំណាចកំពុងជីករណ្តៅកប់ខ្លួនឯង

**ដោយ : អ៊ុម លឿម**

**ហ្វីឡាដែលហ្វៀ :** ក្រោយពីដំណើរទស្សនៈកិច្ចរបស់លោកអគ្គលេខាធិការគណបក្សសិទ្ធិមនុស្ស និង ជាតំណាងរាស្ត្រមណ្ឌលព្រៃវែង គឺលោក យ៉ែម ប៉ុណ្ណារិទ្ធ មកកាន់ទីក្រុងហ្វីឡាដែលហ្វៀ ទើប តែបានប្រមាណជាពីរសប្តាហ៍ប៉ុណ្ណោះ ស្រាប់តែមេបក្សសិទ្ធិមនុស្ស គឺលោក កឹម សុខា ជាតំណាងរាស្ត្រមណ្ឌលកំពង់ចាមផងនោះ បានបង្ហាញនូវវត្តមានរបស់ខ្លួនជាថ្មីលើទឹកដីហ្វីឡាម្តងទៀត បន្ទាប់ពីមេបក្សប្រឆាំងនេះបានធ្វើដំណើរ ដើម្បីចូលរួមធ្វើសមាជបក្សលើកទី៤ របស់ខ្លួនកាលពីខែមេសាកន្លងមកនេះ។

ថ្លែងទៅកាន់សមាជិក សមាជិកាគាំទ្រ និងអ្នកចូលរួមស្តាប់ប្រមាណជា១០០នាក់ នៅក្នុងសាលដ៏ធំទូលាយនៃវត្ត "ព្រះពុទ្ធរង្សី" កាលពីថ្ងៃអាទិត្យទី ១៦ ខែតុលាកន្លងមកនេះ លោក កឹម សុខា បានបង្ហាញនូវក្តីព្រួយបារម្ភរបស់លោក ចំពោះការលិចលង់កាន់តែធ្ងន់ធ្ងរទៅៗរបស់ប្រទេសជាតិ ព្រោះដោយសារ ការកាន់អំណាចរបស់គណបក្សប្រជាជនកម្ពុជា ដែលបណ្តាលឱ្យកើតមានបញ្ហាស៊ីសំណូកសូកប៉ាន់ ពុករលួយ បក្ខពួកនិយម ការហូរចូលនៃអនិកជនយួនខុសច្បាប់ បញ្ហាព្រំដែន ការផ្តល់ដីសម្បទានឱ្យក្រុមហ៊ុនឯកជនបរទេសក្នុងរយៈពេលយូរ ការដេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋានដោយគ្មានសំណងសមស្រប ។ល។ ទាំងអស់នេះជាក្តីកង្វល់របស់លោក កឹម សុខា ថ្លែងទៅកាន់អ្នកចូលរួមស្តាប់។

លោកបន្តថា "តាមរយៈការកាន់អំណាចរបស់គណបក្សប្រជាជនកម្ពុជា ដែលផ្តើមចេញពីការដឹកនាំបែបពហុបក្ស រហូតដល់ឯកបក្ស និងចុងក្រោយគឺរបបផ្តាច់ការនោះមានន័យថា គណបក្សប្រជាជនកម្ពុជា កំពុងតែជីករណ្តៅកប់ខ្លួនឯងហើយ បើគេមើលមួយភ្លែតគេប្រាកដជាច្រឡំថា ប្រទេសកម្ពុជាមានឯករាជ្យ ឬជាប្រទេសប្រកាន់របបប្រជាធិបតេយ្យ ប៉ុន្តែតាមពិត គឺពុំមែនឡើយដោយឯករាជ្យ និងប្រជាធិបតេយ្យមានតែសំបកក្រៅប៉ុណ្ណោះ ហើយបច្ចុប្បន្នបក្សប្រជាជនកម្ពុជា កំពុងមានទំនាស់ផ្ទៃក្នុងដែលផ្តើមចេញពីការចែកផលប្រយោជន៍គ្នាពុំត្រូវ...។ នេះជាការថ្លែងអះអាងរបស់លោក កឹម សុខា។

គួរកត់សំគាល់ផងដែរថា ក្នុងកិច្ចសំណេះសំណាលទៅកាន់អ្នកចូលរួមដ៏សន្ធឹកសន្ធាប់ក្នុងទីក្រុងហ្វីឡាដែលហ្វៀ នាពេលនោះលោក សុខា ពុំបានធ្វើអត្ថាធិប្បាយ ឬរិះគន់ដាក់អតីតដៃគូរសម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យដើម្បីការផ្លាស់ប្តូរ គឺគណបក្ស សម រង្ស៊ី ដូចគ្រាមុនៗឡើយ តែផ្ទុយទៅវិញមេបក្សប្រឆាំងដ៏ធំទីពីរនេះនៅតែបន្តនូវការវាយប្រហារដល់ គណបក្សប្រជាជនកម្ពុជា ដែលដឹកនាំដោយលោក ហ៊ុន សែន យ៉ាងចាស់ដៃដដែល ។

ដោយឡែកក្នុងកិច្ចសម្ភាសន៍មួយ ជាមួយអ្នកកាសែតនាពេលថ្មីៗកន្លងមកនេះលោក គង់ គាំ ប្រធានស្តីទីនៃគណបក្ស សម រង្ស៊ី ហាក់នៅបន្តវាយប្រហារដល់គណបក្សសិទ្ធិមនុស្ស ថាជាបក្សដែលបង្កើតឡើង និងឧបត្ថម្ភដោយគណបក្សប្រជាជនកម្ពុជា ។ "ចាប់ពីពេលនេះតទៅគ្មានទេសម្ព័ន្ធភាពជាមួយបក្សសិទ្ធិមនុស្ស"។ នេះជាការថ្លែងរបស់លោក គង់ គាំ។






ក្នុងស្ថានភាពជាក់ស្តែងចំពោះគណបក្ស សម រង្ស៊ី ត្រូវបានអ្នកវិភាគឯករាជ្យ និងអ្នកតាមដានព្រឹត្តិការណ៍នយោបាយកម្ពុជាកត់សំគាល់ថា បក្សប្រឆាំងមួយនេះ កំពុងធ្វើដំណើរទៅកាន់ភាពរិចរិល និងថមថយដែលការចុះខ្សោយទាំងនោះបណ្តាលមកពីជម្លោះផ្ទៃក្នុងបក្ស ការមិននៅក្នុងស្រុករបស់មេបក្ស និងភាពមានអំនួតរបស់លោក សម រង្ស៊ី តែម្តង ។ ទាំងអស់នេះជាដើមចមដែលបណ្តាលឱ្យបក្ស សម រង្ស៊ី ចុះខ្សោយនូវចំនួនអ្នកគាំទ្រ ហើយជាញឹកញយសកម្មជនរបស់បក្ស សម រង្ស៊ី សំខាន់ៗជាច្រើនរូបត្រូវបានដើរចេញពីគណបក្ស សម រង្ស៊ី ដើម្បីមកចូលរួមជាមួយបក្សសិទ្ធិមនុស្ស របស់លោក កឹម សុខា៕

Neighborhood Health Plan of Rhode Island

តើលោកអ្នកត្រូវការធានារ៉ាប់រងផ្នែកសុខភាពឬ?
សូមទូរស័ព្ទទាក់ទងក្រសួងណេបើរហ៊ូដថ្ងៃនេះ

Need Health Insurance?
Call Neighborhood Today
1-401-459-6171
www.nhpri.org



តមកពីទំព័រទី ៣

## សម្បត្តិនៃ...

កូនប្រុសស្រីទាំងអស់ដែលនៅក្នុងបន្ទុក រីឯម្ដាយ ឬឪពុកចាស់ក៏អាចនៅក្នុងបញ្ជីគ្រួសារតែមួយបានដែរ ឱ្យតែមានសំបុត្របញ្ជាក់ពីពេទ្យថា ម្ដាយ ឬឪពុកនោះនៅក្នុងបន្ទុកនៃកូនជាមេគ្រួសារបានន័យថា បង់១០ដុល្លារ គឺបានចូលជាសមាជិក **"មរណសង្គហសមាគម"** បាន១គ្រួសារ"។ បញ្ជាក់បន្ថែមសមាជិកភាពនោះត្រូវបាត់បង់ទៅវិញនៅពេលមិនបានចូលបុណ្យសព១០ដុល្លារ បីដងផ្ទួនៗគ្នា ហើយសមាជិកដែលទើបតែដាក់ពាក្យចូលត្រូវរង់ចាំពេលបីខែ ទើបមានសិទ្ធិទទួលប្រាក់បំណាច់ ៧០ភាគរយនៃបេឡានៅពេលខ្លួនស្លាប់បាន រីឯអ្នកដែលសុំចូលជាសមាជិកយឺតពេលពេកដូចជា សុំចូលជាសមាជិកនៅអាយុ៨០ឆ្នាំហើយ គឺត្រូវរង់ចាំទទួលបុព្វសិទ្ធិចំនួនបីខែ ហើយអាចទទួលប្រាក់ពីបេឡាចំនួនតែ៥០ភាគរយទេ។



ឈឿន ផល ហិរញ្ញាញឹក

**ចំពោះអ្នកដែលមិនមែនជាសមាជិក :**

ព្រះតេជគុណ វង្ស មុនី បានបញ្ជាក់ថា "ថ្វីត្បិតតែមានអ្នកស្លាប់ខ្លះពុំមែនជាសមាជិកវត្តព្រះពុទ្ធរង្សីបានសន្សំថវិកាខ្លះពីបេឡា៣០ភាគរយពីបេឡា៥០ភាគរយទៅជួយធ្វើបុណ្យសពក្នុងបុព្វសិទ្ធិដូចគ្នានឹងអ្នកជាសមាជិកដែរ តែពុំមានទទួលថវិកាប្រមូលពីសមាជិកណាមួយនោះទេ តែបើមានគេចូលបុណ្យសពប្រាក់នោះនឹងបានទៅគ្រួសារសពដូចគ្នា។

លោក ស៊ិន សុវណ្ណ បានរំលឹកថា សមាជិកសមាគមយើងមាន ៦០០នាក់ហើយ ក្នុងចំនួននោះមានប្រមាណ៣០នាក់ ដែលច្រើនតែមានការយឺតយ៉ាវក្នុងការបង់វិភាគទាន យើងបានធ្វើការអនុគ្រោះដោយយោគយល់ពន្យារពេលឱ្យលើសពីវិភាគទានចំពោះសពចំនួន ៥ ក៏មានដូច្នេះសូមអំពាវនាវឱ្យមេត្តាផ្ញើរវិភាគទានឱ្យបានរហ័សតបនឹងលិខិតយើងខ្ញុំ។

**កំណត់បញ្ជាប់ :** សកម្មភាពមរណសង្គ្រោះនេះ កើតឡើងពីការផ្ដួបកម្លាំងសមាជិកមកពីវត្តព្រះពុទ្ធរង្សី និងលោក អ៊ូ កៅ ដែលបាននាំយកសមាគមរបស់ខ្លួនមកបញ្ចូលជាសមាជិករបស់វត្ត ដែលធ្វើឱ្យ "មរណសង្គហសមាគម" មានកម្លាំងនឹងលទ្ធភាពខ្លាំងជាងមុនក្នុងការជួយដល់គ្រួសារ ដែលមានមនុស្សស្លាប់ ឬក៏ជួយដល់ចាស់ៗ ។ សកម្មភាពដែលជួយមនុស្សឱ្យគិតដល់សេចក្ដីថ្លៃថ្នូរ បន្ទាប់ពីជីវិតបានបញ្ចប់ទៅហើយ គឺគួរឱ្យគោរព និងកោតសរសើរ ដូច្នេះសូមសាធារណជនចូលរួមសកម្មភាពនេះឱ្យបានច្រើនកុះករ ៕

**ទូរស័ព្ទលោក ចាន់ សុខុម ២១៥-៣៣៦-៥៥៤៣**


**ANGKOR AUTO SERVICE, INC.**

**ហាងជួសជុលរថយន្ត "អង្គរ"**

**Free Estimate**

**Auto Body and Maintenance**



BODY WORKS

Auto glass and windshields
Auto Frame Straightening and Painting

មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្វ៊ិរិនបានផង យើងផ្ដល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES

State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425



# BX Towing LLC

**"បេអិច" អូសរថយន្ត២៤ម៉ោង**

**215-989-1585**

**Bob**

Fast & Affordale
24Hrs. Services



600 Washington ave., Ste.8
Philadelphia, PA 19147

Fax : 267-371-5177
botwingllc@gmail.com





**ហាងខ្មែរជួសជុលរថយន្ត**

**បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ**

# Rathe's Auto Service

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកិរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្ដាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្ដេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376



# Nationwide

*Insurance & Financial Service*

**ក្រុមហ៊ុនធានារ៉ាប់រង និងហិរញ្ញវត្ថុ**




*Life* *Home* *Health* *Auto* *Bussiness*

- ▸ ធានារ៉ាប់រងជំនួញលោកអ្នក
- ▸ ធានារ៉ាប់រងផ្ទះសម្បែង
- ▸ ធានារ៉ាប់រងសុខភាព
- ▸ ធានារ៉ាប់រងរថយន្ត
- ▸ ធានារ៉ាប់រងជីវិត

**ចុះតម្លៃ ៣០% បន្ថែម បើលោកអ្នកទិញធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា**

600 Washington Ave Suite #8 Philadelphia, PA 19147
Tel: (215) 463-1257 , Fax: (215) 463-2036

តមកពីទំព័រទី៥

# សូមជនជាតិខ្មែរក្រៅប្រទេស...

ដទៃជាច្រើនទៀតដែរ គឺយើងត្រូវតែមានសន្ទានទឹកចិត្តពេញលក្ខណៈជាជនជាតិខ្មែរស្រឡាញ់មាតុភូមិខ្មែរបងប្អូនរួមឈាមខ្មែរទាំងក្នុងទាំងក្រៅប្រទេស ។ ជាពិសេសត្រូវមានផ្តោតអារម្មណ៍ខ្លាំងបំផុតទៅលើភព្វព្រេងសំណាងវាសនានៃមាតុប្រទេស និងជីវិតជនជាតិខ្មែរដែលសព្វថ្ងៃកំពុងតែស្ថិត និងរស់នៅក្រោមអំណាចមេដឹកនាំ១ក្រុមមានដើមកំណើតកើតចេញមកផែនការមេដឹកនាំប្រទេសយួនកុម្មុយនីស្តដែលតែងតែត្របាក់លេបយកទឹកដី និងជនជាតិខ្មែរតាំងពីសម័យរជ្ជកាលស្តេចជ័យជេដ្ឋាទី២ ក្នុងអំឡុងឆ្នាំ១៦២៣មកម្លេះ ។ រហូតមកដល់សព្វថ្ងៃជនជាតិ យួនវៀតណាម និងជាតិសៀមថៃឡង់នៅតែមានមហិច្ឆតាលោភលន់ប្រើកលល្បិចទិញក្បាល និងទឹកចិត្តមេដឹកនាំខ្មែរឱ្យឈ្លក់វង្វេងក្លាយទៅជាអ្នកបំរើកញ្ជះដាច់ថ្លៃរបស់មេដឹកនាំយួន ។

អំពើប្រព្រឹត្តរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កំពុងតែកាន់អំណាចនេះ ពិតប្រាកដណាស់នឹងត្រូវបណ្តាលឱ្យមានមហាគ្រោះថ្នាក់ជាមហន្តរាយដល់មាតុ-ប្រទេស និងជាតិសាសន៍ខ្មែរយើងរួចហើយក្លាយទៅជាប្រទេសជាតិយួនជៀសពុំរួចឡើយ ។

ដោយមើលឃើញ និងដឹងនូវហេតុការណ៍ជាព្រឹត្តការណ៍ខ្មែរនេះហើយ ទើបបណ្តាលឱ្យមានបញ្ញាវ័ន្តសកម្មជន គណបក្សនយោបាយគ្រប់និន្នាការនយោបាយបង្កើតឡើងចាប់តាំងពីថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ គឺជាថ្ងៃដែលសន្ធិសញ្ញាអន្តរជាតិ មានប្រទេសចំនួន១៨ បានចុះហត្ថលេខាទទួលស្គាល់ស្តីអំពីបញ្ចប់សង្គ្រាមបង្រួបបង្រួមជាតិខ្មែរឱ្យឯករាជ្យ សន្តិភាព បូរណភាព អធិប-តេយ្យភាពទឹកដី លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សក្នុងន័យដើម្បីស្វែងរកវិធីសាស្ត្រជួយកែប្រែផ្លាស់ប្តូរប្រព័ន្ធនយោបាយដឹកនាំប្រទេសជាតិឱ្យចេញពីកណ្តាប់ដៃគណបក្សកុម្មុយនីស្តប្រជាជនកម្ពុជា ដែលមានលោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រី ។

រហូតមកដល់ថ្ងៃនេះ ប្រទេសខ្មែរមានគណបក្សប្រឆាំងខិតខំអំពាវនាវពន្យល់ណែនាំឱ្យបណ្តាមហា-ជនជាតិខ្មែរទាំងក្នុងទាំងក្រៅប្រទេសភ្ញាក់រលឹក ងើបក្រោកឈរឡើង រួបរួមកម្លាំងសាមគ្គីគ្នាឱ្យបង្កើតបានជាកម្លាំងខ្លាំង ទៅជាគណបក្សធំមានជ័យជំនះក្នុងការបោះឆ្នោតជ្រើសរើសមេដឹកនាំប្រទេសជាតិថ្មី ទៅផ្លាស់ប្តូរនាយករដ្ឋមន្ត្រី ហ៊ុន សែន ឱ្យចេញពីអំណាចរួចហើយនាំយកនាយករដ្ឋមន្ត្រីថ្មី ដែលប្រកាន់យកគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សពិតប្រាកដយកលំនាំជាគំរូតាមដូចគ្នានៅក្នុងសហរដ្ឋអាមេរិកដែរ ។

សូមជម្រាបបញ្ជាក់ថា នៅក្នុងគ្រប់អរិយប្រទេសលោកសេរីប្រជាធិបតេយ្យ ការផ្លាស់ប្តូរមេដឹកនាំកំពូលដោយសន្តិវិធី និងអហិង្សាត្រូវតែធ្វើទៅតាមរយៈគណបក្សនយោបាយ ។ លុះដល់ពេលបោះឆ្នោតត្រូវតែនាំគ្នាជ្រើសរើសយកគណបក្សជាទីពេញចិត្តនោះឱ្យបានឈ្នះគេ ទើបផ្លាស់ប្តូរមេដឹកនាំចាស់នោះចេញពីតំណែងបាន ។ ដូច្នេះនៅត្រង់ចំណុចនេះបានបញ្ជាក់បង្ហាញថា ពុំមែនអង្គការក្រៅរដ្ឋាភិបាលណា អង្គការចលនាណាដែលមានកម្លាំងអំណាចស្របច្បាប់នោះបានទេលើកលែងតែមេដឹកនាំខ្លះផ្តាច់ការរំលោភបំពានច្បាប់រដ្ឋ-ធម្មនុញ្ញ និងមិនគោរពសន្ធិសញ្ញាអន្តរជាតិដែលខ្លួនបានចុះហត្ថលេខាហើយនោះចេញ ។

គេសង្កេតឃើញមានបងប្អូនរួមជាតិខ្មែរមួយភាគធំបានមករស់នៅលើទឹកដី ស.រ.អា ក៏ដូចជាក្នុងប្រទេសលោកសេរីនានា តែងតែពោលពាក្យអស់សង្ឃឹមថានៅក្នុងប្រទេសខ្មែរ ពុំឃើញមានប្រធានគណបក្សប្រឆាំងណាមួយ ដែលអាចមានសមត្ថភាព មានប្រាជ្ញាឆ្លៀវឆ្លាត មានគុណសម្បត្តិល្អត្រឹមត្រូវប្រសើរជាងសម្តេច ហ៊ុន សែន សោះឡើយ សូម្បីតែធនធានមនុស្សជាមន្ត្រីក៏គ្មានគ្រប់គ្រាន់ លុយកាក់ ថវិកា ទ្រព្យសម្បត្តិផ្ទាល់ខ្លួនក៏ពុំមានគ្រប់គ្រាន់ដែរ ។ ដូច្នេះកត្តាធំចម្បងទាំងនេះហើយ ដែលជាមូលហេតុបណ្តាលឱ្យគណបក្សប្រឆាំងពុំអាចមានជ័យជំនះក្នុងការបោះឆ្នោតនោះបានសោះឡើយ ។ គេបន្តថា បើប្រធានគណបក្សប្រឆាំងណាហ៊ានធ្វើសកម្មភាពនយោបាយខ្លាំងក្លាទៅលើលោក ហ៊ុន សែន មុខជាត្រូវបាត់ខ្លួនហើយ ឬជាប់គុកហើយរហូតដល់អស់លោកអស់សង្ឃឹមទាំងនោះហ៊ានភ្នាល់ទៀតផងថា គណបក្សប្រឆាំងខំប្រឹងដល់កំរិតណា ក៏នៅតែចាញ់សម្តេចតេជោដែរ កុំឯងធ្វើខ្លាំងអីនោះ ។

ពេលបានឮសំដីនិយាយរបៀបនេះមក ធ្វើឱ្យមានការសោកស្តាយ មិនគួរណាឡើយមានជនជាតិខ្មែរមួយភាគ ដែលបានមករស់នៅលើទឹកដីនៃបិតាលទ្ធិប្រជាធិបតេយ្យឈ្មោះសហរដ្ឋអាមេរិកនេះ ហើយម្តេចឡើយនៅតែមាន **តទៅលេខក្រោយ**


**ក្រុមហ៊ុនធានារ៉ាប់រងដែលបាន**

**បំរើសង្គម២២ឆ្នាំហើយ**

**CONWAY INSURANCE**



For over 23 years, **Conway Insurance Agency** has been your community's one-stop provider of quality insurance services in New England.

We are a **full-service agency** offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត មុខរបរ និងសុខភាព

**យើងនិយាយភាសាខ្មែរ**

CONWAY INSURANCE AGENCY

P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480

**www.ConwayInsurance.com**

សូមសួររក Philip Muth, Philip@ConwayInsurance.com

**East Coast Center**

for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com




**ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមាន អាការៈដូចជា: ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្ទង់ច្រមុះ កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។ និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត**

381 West Broadway South Boston, MA 02127
**(617) 464 - 0001**

**ប័ណ្ណកិញបញ្ជាកាសែតខ្មែរប៉ុស្តិ៍**

ឈ្មោះ និងអាសយដ្ឋានរបស់

ឈ្មោះ :.......................................................

អាសយដ្ឋាន : ..................................................

**ខ្ញុំចង់បាន :**

☐ កាសែតខ្មែរប៉ុស្តិ៍ ១ខែ មាន២លេខ ៦ខែ $30 ១២ខែ $60 ឬ $70 អឺរ៉ូ សម្រាប់អឺរ៉ុប
☐ សៀវភៅឈ្មោះ ..............................តម្លៃ $..................
☐ ស៊ីឌីប្រវត្តិសាស្ត្រខ្មែរ ៤ ម៉ោង តម្លៃមួយសិត $30
ខ្ញុំភ្ជាប់សែក ឬ មនីអដ័រ មក U.A.M.G តម្លៃ $..................
ផ្ញើមក U.A.M.G 438 LINDLEY AVE. PHILADELPHIA, PA 19120
**Phone : 267-253-3947**


SEO RA BOL
Sushi & sasimi
KOREAN • JAPANESE RESTAURANT
(Mon,- Satr: 11am to 11pm)(Sunsay: 11am to 10 pm) www.seorabolphilly.com
BBQ HOUSE
서라벌회관
(215) 924-3355
ភោជនីយដ្ឋានកូរ៉េដ៏ល្បីឈ្មោះនៅហ្វីឡាដែលហ្វៀ
• មានសាច់អាំង "បាបេគ្យូ" របៀបកូរ៉េ
• មានភេសជ្ជៈ "ស្រាវ៉ាញកូរ៉េ" ផ្អែមហើយឆ្ងាញ់គ្រប់ប្រភេទ
សម្រាប់ភ្ញៀវពី១០ទៅ ៨០នាក់
• មានម្ហូបជប៉ុនគ្រប់យ៉ាង-ស៊ូស៊ី ។ល។
• មានបន្ទប់ "ភ្ញៀវកិត្តិយស VIP" បរិយាកាសយ៉ាងប្រសើរ
• មានកន្លែងចតរថយន្តធំទូលាយ
215-924-3355
ភោជនីយដ្ឋានកូរ៉េ
សេអូរេបូល
Seorabol Korean Restaurant
Add: 5734 Old 2nd street
Philadelphia PA 19120


អាហារដ្ឋាន "បហ្វេ"
Mandarin Buffet
Parkway Plaza
1100 Revere Beach Parkway
Chelsea, MA 02150
617-889-0056
WWW.mandarinbuffetma.com
We have a full liquor license
China Buffet
Next to Target
203 Plain St.
Lowell, MA 01852
978-937-8868
WWW.chinabuffetma.com
Beer and Wine only
China Buffet
K-Mart Plaza180 Main
St.Saugus, MA 01906781-231-1588
Beer and Wine only
Buffet includes American & Chinese food bar, Japanese sushi bar, BBQ & grill, fruits,salad bar, ice cream, dessert cakes and much much more!
ALL YOU CAN EAT BUFFET... !!!


SATURDAY
OCT
29
CLUB POLARIS
9pm - 2am
SKY
Halloween
PARTY
$15
FEATURING: PANHAREE THANG & GUEST SINGER: SKY
with KAVEI BAND & SECRET WEAPON BAND
at CLUB POLARIS 460 N 9TH STREET, PHILADELPHIA, PA 19123
WIN PRIZES FOR BEST HALLOWEEN COSTUMES! PARTY TILL 2AM!
Sponsored by KAVEI Xpress
Kavei
EAT IN - TAKE OUT
215.755.2151
AUTHENTIC CAMBODIAN CUISINE
2223-25 S 7TH STREET, PHILADELPHIA, PA 19148